ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំឆ្នាំ២០១៦

នៅក្នុងឆ្នាំ២០១៦នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ៖

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន០២លើក និងទទួលសារតាំង ចំនួន០២លើក

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងកម្មវិធីផ្សេងៗ ចំនួន៥៤លើក

-អញ្ជើញចុះមូលដ្ឋានតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ ចំនួន៥៩លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១៤លើក ប្រជុំពេញអង្គចំនួន០៩លើក និងប្រជុំវិសាមញ្ញចំនួន០១លើក

-បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់បំពេញទស្សនកិច្ចផ្លូវការ និងមិត្តភាពនៅក្រៅប្រទេសចំនួន០២លើក

-អនុញ្ញាតឲ្យគណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ អគ្គទូត និងអង្គការក្រៅរដ្ឋាភិបាលនានា ចូលជួបសម្តែងការគួរសម សវនាការ និងជម្រាបលាចំនួន៣១លើក

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៥៥ ក្រុមប្រឹក្សាធម្មនុញ្ញចំនួន១០ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន០១ និងពីប្រធានរដ្ឋសភាចំនួន០១

-បានទទួលព្រះរាជសារព្រះរាជប្រទានសិទ្ធិចំនួន៦៨ និងបានចុះហត្ថលេខាលើព្រះរាជក្រម ចំនួន០៥ ព្រះរាជក្រឹត្យ ចំនួន៦៣

-បានផ្ញើសំណើក្នុងនាមសម្តេចប្រមុខរដ្ឋស្តីទីចំនួន០១



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៤៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៩៥៦ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០៤លើក

-អញ្ជើញដឹកនាំ និងចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន ១៥លើក ប្រជុំពេញអង្គចំនួន០៧លើក និងប្រជុំវិសាមញ្ញចំនួន០១លើក

-អញ្ជើញចុះមូលដ្ឋានតាមបណ្តាខេត្ត ក្រុង ចំនួន០៦លើក

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងកម្មវិធីផ្សេងៗ ចំនួន២២លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៣២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៨៥០ច្បាប់ ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បានៈ**

-អញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១៨លើក ប្រជុំពេញអង្គចំនួន១០លើក និងប្រជុំវិសាមញ្ញចំនួន០១លើក

-អញ្ជើញចូលរួមប្រជុំការងារសមាគមន៍មិត្តភាពកម្ពុជា-ចិនចំនួន០២លើក

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងកម្មវិធីផ្សេងៗ ចំនួន៥១លើក

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃនៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តពោធិ៍សាត់ ខេត្តស្ទឹងត្រែង និងខេត្តតាកែវ ចំនួន១៦លើក ប្រជាពលរដ្ឋសរុបចំនួន៥.៧១៦នាក់

-អញ្ជើញចុះមូលដ្ឋានតាមបណ្តាខេត្ត ក្រុង ចំនួន៣២លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១.១៣៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១.០៨៨ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា**

-បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១៨លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន១០លើក ប្រជុំវិសាមញ្ញចំនួន០១លើក និងបានពិនិត្យឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១៩ ដែលព្រឹទ្ធសភាទទួលបានពីរដ្ឋសភា ។

## ៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

-ក្នុងឆ្នាំ២០១៦នេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម ៖

### ៣.១ មុខងារនីតិកម្ម

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ចំនួន១៩

-គណៈកម្មការពិសេសប្រជុំពិនិត្យអំពីការរៀបចំសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា ឯកសារ និងនីតិវិធីពាក់ព័ន្ធ

-ប្រជុំក្រុមការងារបច្ចេកទេសដើម្បីពិនិត្យ និងធ្វើឯកសារស្តីពី សេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា ។

### ៣.២ មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-អញ្ជើញចុះជួបសវនាការជាមួយថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិ ដើម្បីតាមដានការអនុវត្តសកម្មភាពការងារដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការជំនាញនានា។

-អញ្ជើញចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន២៦លើក ដើម្បីសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន និងសិក្សាឈ្វេងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងការដោះស្រាយពាក្យបណ្តឹងរបស់ថ្នាក់ក្រោមជាតិ ការអនុវត្តច្បាប់វិឌ្ឍនភាពសំខាន់ៗ និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធជាមួយវិស័យអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ វិស័យសុខភាព ការអនុវត្តច្បាប់ស្តីពី ការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ច្បាប់ស្តីពី ការគ្រប់គ្រងឱសថ និងច្បាប់ស្តីពី ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជ

សាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ការអនុវត្តច្បាប់ផ្លូវថ្នល់ ច្បាប់ចរាចរណ៍ផ្លូវគោក ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្តោតលើមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក-ក្រុង ការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដីស្រុក-ក្រុង និងការដោះស្រាយវិវាទផ្សេងៗ ការចូលរួមអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌក្នុងវង្វង់ដែនសមត្ថកិច្ច ការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ ការផ្គត់ផ្គង់ទឹកស្អាត និងការបែងចែកអគ្គិសនី ព្រមទាំងការលើកកម្ពស់សេវាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ និងបញ្ហាប្រឈមនានា នៅខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តក្រចេះ ខេត្តព្រះសីហនុ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តកែប ខេត្តកំពត ខេត្តកំពង់ធំ ខេត្តសៀមរាប និងរាជធានីភ្នំពេញ។

### ៣.៣ មុខងារតំណាង

-រៀបចំវេទិកាថ្នាក់ខេត្ត និងថ្នាក់ស្រុកចំនួន១១លើក នៅខេត្តបាត់ដំបង ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តព្រៃវែង ខេត្តរតនគិរី ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម និងនៅរាជធានីភ្នំពេញស្តីពី ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការអភិវឌ្ឍស្រុក-ខណ្ឌ និងភូមិ ឃុំមានសុវត្ថិភាព លើកកម្ពស់ និងជម្រុញការអភិវឌ្ឍឃុំ-សង្កាត់ វឌ្ឍនភាពស្ត្រីក្នុងវិស័យនយោបាយ ការបង្កើនសមត្ថភាពក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការអភិវឌ្ឍមូលដ្ឋាន ការអនុវត្តមុខងារ និងនីតិវិធីនៃការប្រើប្រាស់ថវិកាគណៈកម្មាធិការទទួល បន្ទុកកិច្ចការនារី និងកុមារ សេវាសាធារណៈការផ្គត់ផ្គង់ទឹកប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ ការធ្វើអត្តសញ្ញាណប័ណ្ណ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងភូមិ-ឃុំ មានសុវត្ថិភាពនៅថ្នាក់មូលដ្ឋាន ពិគ្រោះយោបល់ដើម្បីផ្សព្វផ្សាយនូវសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភា និងឈ្វេងយល់បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។

-ទទួលពាក្យបណ្តឹងចំនួន៦៩ករណី បញ្ជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន៥៦ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងចំនួន១៦ករណី តំកល់ទុកមិនចាត់ការចំនួន០៤ករណី និងដោះស្រាយបញ្ចប់ ០១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន១៦ ករណី និងធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន១៥ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធបានចំនួន ៨៤ករណី ។

-ថ្នាក់ដឹកនាំក្រុមភូមិភាគ និងសមាជិក សមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់ធ្វើសកម្មភាពជីកអណ្តូង ជីកស្រះទឹក ស្តារស្រះទឹក នៅតាមបណ្តាខេត្តនានា ដូចជាខេត្តកណ្តាល ព្រៃវែង កំពង់ស្ពឺ ត្បូងឃ្មុំ កំពង់ចាម តាកែវ កំពត និងរាជធានីភ្នំពេញបានចំនួន០៨អណ្តូង និងស្រះទឹកចំនួន១២ ។

-សមាជិក សមាជិកាព្រឹទ្ធសភាបានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១.៨២២លើក ដើម្បីជួបពិភាក្សា សំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ កងទ័ព និវត្តន៍ជន លោកគ្រូ អ្នកគ្រូ សិស្ស និស្សិតជាពិសេសពិនិត្យមើលអំពីដំណើរការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីថ្មី ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្សការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋានផ្សព្វផ្សាយព័ត៌មាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗសរុបចំនួន៧០០លើក ។

**៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

ថ្នាក់ដឹកនាំ សមាជិក-សមាជិកាគណៈកម្មការនានារបស់ព្រឹទ្ធសភា បានអញ្ជើញទៅបំពេញបេសកកម្មចំនួន៤១លើក ដើម្បីចូលរួមកិច្ចប្រជុំ ទស្សនកិច្ចសិក្សា សន្និបាតសន្និសីទ សិក្ខាសាលា វេទិកា និងពិធីផ្សេងៗ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋសង្គមនិយមវៀតណាម ព្រះរាជាណាចក្រជប៉ុន សាធារណរដ្ឋ

ប្រជាមានិតចិន ព្រះរាជាណាចក្រហូឡង់ ប្រទេសសិង្ហបុរី ប្រទេសម៉ាឡេស៊ី សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋបារាំង សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ព្រះរាជាណាចក្រថៃឡង់ដ៍ ប្រទេសប៊ែលហ្ស៊ិក ប្រទេសអ៊ីរ៉ង់ ប្រទេសកាណាដា ប្រទេសម៉ុងហ្គោលី ប្រទេសស៊ុយអែត ប្រទេសស៊ីប៊ី ប្រទេសឥណ្ឌា សហរដ្ឋអាមេរិក ប្រទេសម៉ាដាហ្គាស្កា ប្រទេសហូឡង់ ប្រទេសស្វីស ប្រទេសលុចហ្សំបួរ និងប្រទេសអូស្ត្រាលី។

រាជធានីភ្នំពេញ,ថ្ងៃទី១៨ខែមករា ឆ្នាំ២០១៧

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ